# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៣៧...អនក្រ.បក

## អនុក្រឹត្យ

## ស្តីពី

## ការលុប និងកាត់បន្ថយដែនវនេសាទបន្ថែមទៀតក្នុងនាទីឡូត៍នេសាទ ខេត្តកណ្ដាល ទុកសម្រាប់ប្រជាពលរដ្ឋធ្វើនេសាទជាលក្ខណៈគ្រួសារ

*******

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស / រកត / ១១៩៨ /៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២ / នស /៩៤ / ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ នស / រកម / ០១៩៦ / ១៣ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើត ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

-បានឃើញក្រឹត្យច្បាប់លេខ ៣៣ ក្រច ចុះថ្ងៃទី ០៩ ខែ មីនា ឆ្នាំ ១៩៨៧ ស្តីពីការគ្រប់គ្រងវិស័យជលផល

-បានឃើញអនុក្រឹត្យលេខ ១៧ អនក្រ . បក ចុះថ្ងៃទី ០៧ ខែ មេសា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

-បានឃើញអនុក្រឹត្យលេខ ០៦ អនក្រ.បក ចុះថ្ងៃទី ២២ ខែមករា ឆ្នាំ ២០០១ ស្តីពីការលុបនាទីឡូត៍នេសាទនិងកាត់បន្ថយដែននេសាទក្នុងនាទីឡូត៍នេសាទខេត្តកណ្ដាល ទុកសម្រាប់ប្រជាពលរដ្ឋធ្វើនេសាទជាលក្ខណៈគ្រួសារ

-បានទទួលការឯកភាពពីសម័យប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី នាថ្ងៃទី ១៤ ខែ វិច្ឆិកា ឆ្នាំ ២០០៣

## សម្រេច

**មាត្រា១ .-**

ត្រូវបានលុបចេញនាទីឡូត៍នេសាទ និងកាត់បន្ថយដែននេសាទបន្ថែមទៀតក្នុងនាទីឡូត៍នេសាទខេត្តកណ្ដាលទុកសម្រាប់ប្រជាពលរដ្ឋធ្វើនេសាទជាលក្ខណៈគ្រួសារមានដូចខាងក្រោម :

១-លុបឡូត៍នេសាទឆ្នេរខ្សាច់ លេខ ០១ ចេញពីនាទីឡូត៍នេសាទចាប់ពីរដូវនេសាទ ឆ្នាំ ២០០៣-២០០៤ តទៅ ។

២-កាត់ចេញពីនាទីឡូត៍នេសាទនៃផ្ទៃដែននេសាទក្នុងខេត្តកណ្តាល និងកំណត់ព្រំប្រទល់ឡូត៍នេសាទជាថ្មីចាប់ពីពេលនេះតទៅ ÷

-ឡូត៍នេសាទបឹងព្រែក លេខ ០១ ត្រូវកាត់ចេញ ២៦ ហ.ត

-ឡូត៍នេសាទលេខ ០៨ ត្រូវកាត់ចេញ ១៤២ ហ.ត

-ឡូត៍នេសាទ លេខ ០៩ ត្រូវកាត់ចេញ ៥៩ ហ.ត

-ឡូត៍នេសាទ លេខ ១៨ ត្រូវកាត់ចេញ ១.៨៦៨ ហ.ត ។

៣-ឡូត៍នេសាទ លេខ ០៨ និង ឡូត៍នេសាទលេខ ០៩ ត្រូវបានបញ្ចូលគ្នារៀបចំជែនទីឡូត៍នេសាទលេខ ០៩ ថ្មី ។ តារាង និងផែនទីភ្ជាប់ជាមួយ ឧបសម្ព័ន្ធ។

**មាត្រា២ ._**

ដែននេសាទដែលបានលុបចោលនិងកាត់ចេញពីនាទីឡូត៍នេសាទ ត្រូវប្រគល់ជូនប្រជាពលរដ្ឋប្រកបរបរនេសាទជាលក្ខណៈគ្រួសារ ។

ហាមដាច់ខាតមិនឱ្យបុគ្គលណាមួយហួងហែងយកទៅលក់ឬជួលធ្វើអាជីវកម្មផ្តាច់មុខឡើយ ។

**មាត្រា៣ ._**

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ត្រូវរៀបចំសហគមន៍នេសាទដើម្បីគ្រប់គ្រងដែននេសាទដែលបានលុប និងកាត់ចេញពីនាទីឡូត៍នេសាទនេះ ។

**មាត្រា៤ ._**

បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍។

**មាត្រា៥ ._**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួងស្ថាប័នដែលពាក់ព័ន្ធ និងអភិបាលខេត្តកណ្តាល ត្រូវអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀង១ខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ២៧ ខែវិច្ឆិកា ឆ្នាំ ២០០៣

ហ៊ុន សែន

<u>កន្លែងទទួល :</u>

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចមាត្រា ៥
-ឯកសារ-កាលប្បវត្តិ


ផែនទី ឡូត៍នេសាទលេខ ០១ ខេត្តកណ្ដាល
សំរាប់ភ្ជាប់ជាមួយអនុក្រឹត្យ លេខ.៧៦..អនក្រ.បក ចុះថ្ងៃទី.២៦...ខែ.វិច្ឆិកា ឆ្នាំ ២០០៣
រៀបចំដោយការិយាល័យកិច្ចការផែនទីនេសាទ និងផ្សព្វផ្សាយ
នាយកដ្ឋានជលផល
TONLE BASAK (BASSAC)
Ph Kbal Kaoh
Ph Kandal Kaoh (1)
Ph Prek Tea...
Ph Kaoh Kaabel
Ph Svay Rolum
Ph Prek Teahean Sau
Ph Rokar Kpong
Ph Svay Rolum
Ph Prek Ta Rang
KANDAL STUENG
PREK TOK CHOU
គំណត់សំគាល់
ព្រំប្រទល់ស្រុក
ផ្លូវលំ
ទន្លេ-ស្ទឹង-ព្រែក
របាំងមួស់
ព្រៃរបោះ
ស្រែ-ទំនាប់បឹង
បឹង-ត្រពាំង
ព្រៃលិចទឹក
ព្រំប្រទល់ឡូត៍នេសាទ ( ២.៤២៤ ហ.ត )
ដែននេសាទសំរាប់ប្រជាពលរដ្ឋ ( ៦.៣៤៨ ហ.ត )
មាត្រដ្ឋាន ១:៥០ ០០០

៦

# ផែនទី ឡូត៍នេសាទលេខ ០៨ និង ០៩ ខេត្តកណ្តាល ដែលបានកាត់បន្ថែម

រៀបចំដោយការិយាល័យកិច្ចការដែននេសាទ និងផ្សព្វផ្សាយ
នាយកដ្ឋានជលផល




តំណាងសំគាល់

- ព្រំប្រទល់ស្រុក
- ផ្លូវ
- ទន្លេ-ស្ទឹង-ព្រែក
- របាំងឬស្ស
- ស្រែ-ទំនាប់បឹង
- បឹង-ត្រពាំង
- ព្រៃលិចទឹក
- ព្រៃគម្ពោត
- ព្រំប្រទល់ឡូត៍នេសាទ
- ដែននេសាទសំរាប់ប្រជាពលរដ្ឋ
- ដែននេសាទដែលបានកាត់បន្ថែមសំរាប់ប្រជាពលរដ្ឋ

ជ ខ ត ឧ

មាត្រដ្ឋាន ១:៥០.០០០

៥

# ផែនទី ឡូត៍នេសាទលេខ ០៩ ខេត្តកណ្ដាល

សំរាប់ភ្ជាប់ជាមួយអនុក្រឹត្យ លេខ៧៦.....អនក្រ.បក ចុះថ្ងៃទី២៦.....ខែវិច្ឆិកា.ឆ្នាំ ២០០៣

រៀបចំដោយការិយាល័យកិច្ចការដែនទេសាទ និងផ្សព្វផ្សាយ
នាយកដ្ឋានជលផល




**តំណាងសំគាល់**

- ព្រំប្រទល់ស្រុក
- ផ្លូវលំ
- ទន្លេ-ស្ទឹង-ព្រែក
- របាំងចាស់
- ស្រែ-ទំនាប់បឹង
- បឹង-ត្រពាំង
- ព្រៃលិចទឹក
- ព្រៃកម្លោត
- ព្រំប្រទល់ឡូត៍នេសាទ (២.៩៥៩ ហ.ត)
- ដែនទេសាទសំរាប់ប្រជាពលរដ្ឋ (៦.៦០៥ ហ.ត)

ជ ខ ត ល

មាត្រដ្ឋាន ១:៥០.០០០

១ ០ ១ គ.ម



